NDIS Quality and Safeguards Commission

NDIS Workforce Capability Framework

# កញ្ចប់ព័ត៌មានស្ដីពីក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម NDIS

Khmer | ភាសាខ្មែរ

## សៀវភៅមគ្គុទ្ទេសក៍អំពីក្របខ័ណ្ឌ

ខែមេសា ឆ្នាំ 2023

# ទិដ្ឋភាពទូទៅ

ឯកសារនេះត្រូវបានសរសេរដោយគណៈកម្មការត្រួតពិនិត្យគុណភាព និងការការពារ NDIS។

ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម NDIS (ក្របខ័ណ្ឌ) ត្រូវបានបង្កើតឡើងជាមួយនឹងការពិគ្រោះយោបល់យ៉ាងសំខាន់ ហើយមានតម្លៃសម្រាប់អ្នកចូលរួម អ្នកផ្តល់សេវា និងបុគ្គលិកដែលចូលរួមពាក់ព័ន្ធក្នុងគម្រោងធានារ៉ាប់រងជនពិការថ្នាក់ជាតិ (NDIS)។ ការរួមចំណែកក្នុងការរចនា និងការអភិវឌ្ឍន៍នៃក្របខ័ណ្ឌនេះ រួមទាំងមតិកែលម្អក៏ត្រូវបានទទួលស្គាល់ថាបានបញ្ចូលនៅក្នុងដំណើរការនេះ។

ក្របខណ្ឌនេះក៏អាចជួយអ្នកទាំងនោះដែលគិតអំពីអាជីព ដែលផ្តល់នូវការពេញចិត្តនៅក្នុងវិស័យពិការភាព ហើយបណ្តាអង្គការសិក្សា និងបណ្តុះបណ្តាលអាចប្រើប្រាស់ក្របខ័ណ្ឌនេះ ដើម្បីជួយរៀបចំកម្មវិធីសិក្សារបស់ពួកគេតាមវិធីថ្មីនៅក្នុងការផ្តល់ការគាំទ្រជនពិការតាមរយៈ NDIS។

កញ្ចប់ផ្សព្វផ្សាយនេះផ្តល់នូវព័ត៌មានបន្ថែមអំពីក្របខ័ណ្ឌ គោលបំណងរបស់វា របៀបដែលវាអាចប្រើបាន គុណតម្លៃរបស់វា និងសេចក្តីសង្ខេបនៃធនធាននានាដែលមាន។ មានឧបករណ៍ សៀវភៅមគ្គុទ្ទេសក៏នានាដែលអាចទាញយកបាន និងទម្រង់គំរូដែលគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌនេះដោយអ្នកប្រើប្រាស់ផ្សេងៗគ្នារួមមានអ្នកផ្តល់សេវា បុគ្គលិក អ្នកស្វែងរកការងារ និងអ្នកចូលរួម។

នៅពេលណាដែលទិដ្ឋភាពនៃក្របខ័ណ្ឌខ្លួនឯងត្រូវបានសរសេរចេញពីទស្សនៈរបស់អ្នកចូលរួម វានឹងមានឧទាហរណ៍មួយ ហើយឧបករណ៍នេះនឹងបញ្ជាក់យ៉ាងច្បាស់ថា 'ខ្ញុំ', 'អ្នក' ឬ 'យើង' នៅពេលពាក់ព័ន្ធ។

សូមចូលមើល គេហទំព័រក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម សម្រាប់បណ្តាឧបករណ៍ធនធាន និងព័ត៌មានថ្មីៗបំផុត។

# ក្នុងកញ្ចប់នេះ៖

ទិដ្ឋភាពទូទៅ ........ 1
តើអ្វីទៅជាក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម? ........ 3
តើអ្នកណាត្រូវបានពិគ្រោះយោបល់នៅពេលបង្កើតក្របខ័ណ្ឌនេះ? ........ 4
តើក្របខ័ណ្ឌនេះអាចត្រូវបានប្រើប្រាស់ដោយរបៀបណា? ........ 4
តើអ្នកណាអាចប្រើប្រាស់ក្របខ័ណ្ឌនេះបាន? ........ 5
ឧបករណ៍ និងធនធាននានាសម្រាប់បុគ្គលិក ........ 7
សៀវភៅមគ្គុទេសក៍ជម្រើសអាជីព ........ 7
ឧបករណ៍វាយតម្លៃខ្លួនឯងសម្រាប់បុគ្គលិកដែលមានសក្តានុពល ........ 7
ឧបករណ៍ និងធនធាននានាសម្រាប់អ្នកចូលរួម ........ 8
ធនធានសម្រាប់អ្នកចូលរួម ........ 8
ឧបករណ៍ និងធនធានសម្រាប់អ្នកចូលរួម និងអ្នកផ្តល់សេវានានា ........ 9
ឧបករណ៍ពណ៌នាមុខតំណែង ........ 9
ការត្រួតពិនិត្យសមត្ថភាព ........ 9
ធនធានសម្រាប់ការជ្រើសរើសបុគ្គលិក និងការសម្រិតសម្រាំងបុគ្គលិក ........ 10
ឧបករណ៍ និងធនធាននានាសម្រាប់អ្នកផ្តល់សេវា ........ 11
សៀវភៅមគ្គុទេសក៍ស្តីពីការបណ្តុះបណ្តាលសមត្ថភាព ........ 11
ឧបករណ៍គ្រប់គ្រង និងរៀបចំផែនការកម្លាំងពលកម្ម ........ 11
តើក្របខ័ណ្ឌនេះទាក់ទងនឹងក្រមប្រតិបត្តិ និងបទដ្ឋានអនុវត្តយ៉ាងដូចម្តេចដែរ? ........ 12
តើខ្ញុំអាចទាក់ទងអ្នកណាសម្រាប់ព័ត៌មានបន្ថែម? ........ 12

# តើអ្វីទៅជាក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម?

ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម NDIS (ក្របខ័ណ្ឌ) ពណ៌នាអំពីអាកប្បកិរិយា ជំនាញ និងចំណេះដឹងដែលត្រូវបានរំពឹងទុកពីបុគ្គលិកទាំងអស់ដែលបានទទួលមូលនិធិនៅក្រោម NDIS។ វាផ្តល់នូវឧទាហរណ៍ច្បាស់លាស់ជាក់ស្តែងអំពីអាកប្បកិរិយានានាដែលបង្ហាញពីសមត្ថភាពរបស់បុគ្គលិក និងបង្កើតភាសារួមមួយអំពី 'អ្វីដែលល្អមើលទៅមានលក្ខណៈដូចម្តេចដែរ'។ ក្របខ័ណ្ឌនេះត្រូវបានគាំទ្រដោយឧបករណ៍ និងសៀវភៅមគ្គុទ្ទេសក៍នានា ដើម្បីជួយអ្នកផ្តល់សេវា បុគ្គលិកដែលមានស្រាប់ និងបុគ្គលិកដែលមានសក្តានុពល អ្នកស្វែងរកការងារធ្វើ និងអ្នកចូលរួមនានា។

ក្របខ័ណ្ឌ៖

- ត្រូវបានសរសេរចេញពីទស្សនៈរបស់អ្នកចូលរួម NDIS។
- បកប្រែ ក្រមប្រតិបត្តិ និង ស្តង់ដារការអនុវត្ត NDIS ទៅជាអាកប្បកិរិយា និងសមត្ថភាពដែលអាចសង្កេតបានសម្រាប់បុគ្គលិកនៅគ្រប់កម្រិតទាំងអស់។
- ពណ៌នាអំពីឥរិយាបថ ជំនាញ និងចំណេះដឹង (សមត្ថភាព) ដែលត្រូវបានរំពឹងទុកពីបុគ្គលិកទាំងអស់ ដោយផ្តោតខ្លាំងលើការប្រាស្រ័យទាក់ទង និងអន្តរកម្មរវាងបុគ្គលិក និងអ្នកចូលរួម។
- ពណ៌នាអំពី 'អ្វីដែលល្អមើលទៅមានលក្ខណៈដូចម្តេចដែរ' នៅពេលប្រកាន់ខ្ជាប់នូវគុណតម្លៃដែលផ្អែកលើសិទ្ធិរបស់ NDIS ដើម្បីជំរុញការផ្លាស់ប្តូរវប្បធម៌ជាវិជ្ជមាន។
- ត្រូវបានសរសេរដោយផ្តោតលើការរាប់បញ្ចូល ជម្រើស និងការត្រួតពិនិត្យ និងការប្រកាន់ខ្ជាប់នូវសិទ្ធិរបស់មនុស្សដែលមានពិការភាព។
- ពាក់ព័ន្ធនឹងបុគ្គលិកទាំងអស់ដែលផ្តល់ការគាំទ្រ និងសេវាកម្មដែលបានផ្តល់មូលនិធិដោយ NDIS ដល់បណ្តាអ្នកចូលរួម NDIS រួមទាំង៖
  - ការងារគាំទ្រផ្ទាល់ខ្លួនប្រចាំថ្ងៃ (ដូចជាជំនួយជាមួយកិច្ចការប្រចាំថ្ងៃ ឬការថែទាំផ្ទាល់ខ្លួន)
  - ការគាំទ្រឯកទេស ការគាំទ្រការកសាងសមត្ថភាព (ដូចជាការគាំទ្រផ្នែកសុខភាព និងការព្យាបាល)
  - អ្នកដឹកនាំ និងអ្នកគ្រប់គ្រង និង
  - សេវាកម្មជំនួយបន្ទាប់បន្សំ (ដូចជាការថែទាំ ការសម្អាត ឬទទួលភ្ញៀវ)។
- បានរចនាឡើងសម្រាប់អ្នកណាម្នាក់ដែលត្រូវការយល់ដឹង ណែនាំ ឬចូលរួមនៅក្នុងកម្លាំងពលកម្ម NDIS។

ប្រសិនបើបុគ្គលិកនៅគ្រប់កម្រិតបង្ហាញពីសមត្ថភាពដែលមានចែងក្នុងក្របខ័ណ្ឌនេះ អ្នកចូលរួមគួរតែទទួលបានសេវាកម្មប្រកបដោយសុវត្ថិភាព និងគុណភាព ដែលគាំទ្រដល់គោលដៅដែលបានជ្រើសរើសរបស់ពួកគេ។

# តើអ្នកណាត្រូវបានពិគ្រោះយោបល់នៅពេលបង្កើតក្របខ័ណ្ឌនេះ?

ក្របខ័ណ្ឌនេះត្រូវបានបង្កើតឡើងក្នុងរយៈពេលជាង 18 ខែនៃការពិគ្រោះយោបល់ពហុដំណាក់កាលជាមួយមនុស្សជាង 600 នាក់ រួមមាន៖

- អ្នកចូលរួម/អ្នកថែទាំ/សមាជិកគ្រួសារ
- បុគ្គលិកនានា
- អ្នកផ្តល់សេវានានា
- ស្ថាប័នកំពូលនានា
- អ្នកជំនាញបច្ចេកទេស/អ្នកស្រាវជ្រាវ និងអ្នកផ្តល់ការបណ្តុះបណ្តាល។

# តើក្របខ័ណ្ឌនេះអាចត្រូវបានប្រើប្រាស់ដោយរបៀបណា?

ក្របខ័ណ្ឌនេះត្រូវបានសរសេរឡើងតាមសំឡេងរបស់អ្នកចូលរួម ហើយពណ៌នាអំពី 'អ្វីដែលល្អមើលទៅមានលក្ខណៈដូចម្តេចដែរ' សម្រាប់ការផ្តល់ និងទទួលការគាំទ្រនានា។ 'អ្នក' និង 'របស់អ្នក' សំដៅលើបុគ្គលិក ឬអ្នកផ្តល់សេវា ហើយ 'ខ្ញុំ' និង 'ខ្ញុំ' សំដៅលើអ្នកចូលរួម។

ក្របខ័ណ្ឌមានវត្ថុបំណងចំនួនប្រាំ ដែលពណ៌នាអំពីការរំពឹងទុកសមរួលដែលអ្នកចូលរួមមានចំពោះបុគ្គលិក និងអ្នកផ្តល់សេវានានា។

ទាំងនេះរួមបញ្ចូលមាន៖

- ទំនាក់ទំនងរបស់យើង៖ បង្កើតទំនាក់ទំនងរបស់យើងដើម្បីជោគជ័យ។
- ផលប៉ះពាល់របស់អ្នក៖ ដឹងពីសមត្ថភាព តួនាទី និងឥទ្ធិពលរបស់អ្នក។
- គាំទ្រខ្ញុំ៖ គាំទ្រខ្ញុំឱ្យបន្តលើអ្វីដែលសំខាន់សម្រាប់ខ្ញុំ។

- មានវត្តមាន៖ មានវត្តមាន ហើយផ្តល់ការគាំទ្រដែលខ្ញុំត្រូវការ។
- ចូលពិនិត្យ៖ ធ្វើការជាមួយខ្ញុំដើម្បីវាយតម្លៃ និងធ្វើសកម្មភាពលើអ្វីដែលកំពុងដំណើរការ និងអ្វីដែលមិនដំណើរការ។

កំណែគេហទំព័រអន្តរកម្មនៃក្របខ័ណ្ឌ អញ្ជើញអ្នកប្រើប្រាស់ឱ្យជ្រើសរើសប្រភេទការងារដែលពួកគេចង់ពណ៌នា (ទូទៅ កម្រិតខ្ពស់ ជំនួយបន្ទាប់បន្សំ ថ្នាក់គ្រប់គ្រង ភាពជាអ្នកដឹកនាំ) ហើយបង្ហាញសមត្ថភាពពាក់ព័ន្ធនានា។

ឧបករណ៍ និងធនធាននានាដែលគាំទ្រក្របខ័ណ្ឌនេះបានមកពីវិធីសាស្ត្រផ្អែកលើសមត្ថភាពក្នុងការរៀបចំផែនការកម្លាំងពលកម្ម។ ឧបករណ៍នីមួយៗប្រើប្រាស់សមត្ថភាពក្របខ័ណ្ឌតាមវិធីជាក់ស្តែង ដើម្បីបង្កើនគុណភាពកម្លាំងពលកម្ម។

ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម NDIS មាននៅលើអ៊ីនធឺណិត និងជាឯកសារ PDFអាចទាញយកបាន ឬចូលប្រើ ឯកសារ Word បាន។

# តើអ្នកណាអាចប្រើប្រាស់ក្របខ័ណ្ឌនេះបាន?

ក្របខណ្ឌនេះអាចត្រូវបានប្រើប្រាស់ដោយមនុស្សជាច្រើន រួមទាំងបុគ្គលិក អ្នកចូលរួម អ្នកផ្តល់សេវា និងបុគ្គលិកដែលមានសក្តានុពល។

អ្នកចូលរួមដែលចង់ក្លាយជាផ្នែកនៃការជ្រើសរើសបុគ្គលិក ការត្រួតពិនិត្យ ឬផ្តល់មតិកែលម្អអាចប្រើប្រាស់ក្របខ័ណ្ឌនេះ ហើយដូច្នេះអាចគ្រប់គ្រងអ្នកចូលរួមដោយខ្លួនឯងបាន។

បុគ្គលិកដែលចង់ពង្រីកអាជីពរបស់ពួកគេ ឬបុគ្គលិកមានសក្តានុពលដែលចង់មើលថាតើអាជីពគាំទ្រជនពិការអាចមើលទៅមានលក្ខណៈដូចម្តេចដែរ អាចប្រើប្រាស់ក្របខ័ណ្ឌនេះបាន។

អ្នកផ្តល់សេវា និងបុគ្គលិកធនធានមនុស្សអាចប្រើប្រាស់ក្របខ័ណ្ឌនេះដើម្បីរៀបចំផែនការកម្លាំងពលកម្ម និងគ្រប់គ្រង ជ្រើសរើសបុគ្គលិក ត្រួតពិនិត្យ និងកំណត់ជម្រើសនានានៅក្នុងការបណ្តុះបណ្តាលសម្រាប់បុគ្គលិក។

**តើឧបករណ៍ និងធនធានអ្វីខ្លះដែលគាំទ្រក្របខ័ណ្ឌនេះ?**

ក្របខ័ណ្ឌនេះត្រូវបានគាំទ្រដោយឧបករណ៍ និងសៀវភៅមគ្គុទ្ទេសក៍នានាដែលជួយក្នុងផ្នែកនានាដូចជាការរៀបចំផែនការអាជីព ការជ្រើសរើសបុគ្គលិក ការរៀបចំផែនការកម្លាំងពលកម្ម និងការគ្រប់គ្រង និងការអភិវឌ្ឍន៍កម្លាំងពលកម្ម។



# ឧបករណ៍ និងធនធាននានាសម្រាប់បុគ្គលិក

## សៀវភៅមគ្គុទេសក៍ជម្រើសអាជីព

- ជួយបុគ្គលិកក្នុងការស្វែងរកការងារ និងឱកាសអាជីពនានានៅក្នុងវិស័យពិការភាព និងវិស័យពាក់ព័ន្ធនានា។
- ប្រើប្រាស់ក្របខ័ណ្ឌនេះដើម្បីពណ៌នាអំពីការរំពឹងទុកសម្រាប់តួនាទីផ្សេងៗគ្នា ជាមូលដ្ឋានដើម្បីយល់ដឹងពីកន្លែងដែលត្រូវអនុវត្ត និងអភិវឌ្ឍសមត្ថភាព និងចំណាប់អារម្មណ៍នានា។
- ផ្តល់គន្លឹះ និងការណែនាំនានាអំពីរបៀបប្រើប្រាស់សមត្ថភាពការងារគាំទ្រជនពិការទូទៅតាមវិធីថ្មីៗ និងរបៀបពង្រឹងសមត្ថភាពទាំងនេះ ដើម្បីផ្តល់នូវទិដ្ឋភាពនៃការគាំទ្រផ្សេងៗគ្នា ទទួលយកតួនាទីឯកទេសបន្ថែមទៀត ឬផ្លាស់តួនាទីទៅក្នុងមុខតំណែងគ្រប់គ្រងជួរមុខ។
- **មានប្រយោជន៍សម្រាប់៖** បុគ្គលិក NDIS ដែលចាប់អារម្មណ៍ក្នុងការស្វែងរកជម្រើសការងារ និងអភិវឌ្ឍសមត្ថភាព និងអាជីពរបស់ពួកគេបន្ថែមទៀត។

## ឧបករណ៍វាយតម្លៃខ្លួនឯងសម្រាប់បុគ្គលិកដែលមានសក្តានុពល

- ផ្តល់ឱ្យអ្នកស្វែងរកការងារជាមួយនឹងទម្រង់គំនិត អំពីថាតើការធ្វើការនៅក្នុងតួនាទីគាំទ្រជនពិការអាចមើលទៅមានលក្ខណៈដូចម្តេចដែរ។
- ប្រើប្រាស់សំណួរ និងសេណារីយ៉ូជាក់ស្តែងមួយចំនួន ដើម្បីគាំទ្រអ្នកប្រើប្រាស់ឱ្យឆ្លុះបញ្ចាំងពីឥរិយាបថ គុណតម្លៃ និងជំនឿរបស់ពួកគេ ដើម្បីជួយពួកគេសម្រេចចិត្តថាតើពួកគេស័ក្តសមល្អសម្រាប់ការងារក្នុងតួនាទីនៃវិស័យពិការភាពដែរឬទេ។
- កំណត់ការបណ្តុះបណ្តាល ជំនាញ និងបទពិសោធន៍ជីវិតដែលមានស្រាប់ ដែលអាចបំពាក់បរិក្ខារដល់មនុស្សម្នាក់ដើម្បីធ្វើការក្នុងវិស័យពិការភាព។
- ផ្តល់នូវការវាយតម្លៃដែលត្រូវតាមបុគ្គល ជាពិសេសដោយផ្អែកលើការឆ្លើយតបរបស់អ្នកប្រើប្រាស់ និងគូសបញ្ជាក់ពីដំបូន្មានទូទៅអំពីជំហានបន្ទាប់នានាដែលត្រូវអនុវត្ត។
- **មានប្រយោជន៍សម្រាប់៖** មនុស្សដែលកំពុងពិចារណាធ្វើការនៅក្នុង NDIS។

# ឧបករណ៍ និងធនធាននានាសម្រាប់អ្នកចូលរួម

## ធនធានសម្រាប់អ្នកចូលរួម

- ផ្តល់ការណែនាំជាក់ស្តែងសម្រាប់អ្នកចូលរួមអំពីការប្រើប្រាស់ក្របខ័ណ្ឌ និងឧបករណ៍នានាដើម្បីគាំទ្រពួកគេក្នុងការស្វែងរក និងរក្សាបុគ្គលិកដែលពួកគេត្រូវការ។
- ធនធានងាយស្រួលអាន វីដេអូ និងគំនូរជីវចល មានសម្រាប់ឯកសារ និងដំណើរការសំខាន់ៗ។
- សេណារីយ៉ូនានាដែលបង្ហាញពីទិដ្ឋភាពនៃក្របខ័ណ្ឌ និងឧបករណ៍ដែលមានសម្រាប់ប្រើប្រាស់គឺនៅទូទាំងគេហទំព័រ ដើម្បីគាំទ្រអ្នកចូលរួមក្នុងការស្វែងរក និងរក្សាបុគ្គលិក។

# ឧបករណ៍ និងធនធានសម្រាប់អ្នកចូលរួម និងអ្នកផ្តល់សេវានានា

## ឧបករណ៍ពណ៌នាមុខតំណែង

- ណែនាំអ្នកប្រើប្រាស់ឱ្យបង្កើតការពណ៌នាអំពីមុខតំណែងផ្អែកលើសមត្ថភាព។
- ផ្ទុកសមត្ថភាពក្របខ័ណ្ឌដែលពាក់ព័ន្ធដោយស្វ័យប្រវត្តិ ដោយផ្អែកលើតួនាទី និងព័ត៌មានមុខតំណែង។
- មានប្រយោជន៍ក្នុងការបង្កើតនូវការយល់ដឹងដែលមានលក្ខណៈស៊ីសង្វាក់គ្នា និងផ្អែកលើសមត្ថភាពនៃតួនាទីរបស់បុគ្គលិក។
- ផ្តត់ផ្តង់កំណែពីរដែលត្រូវតាមបុគ្គលជាពិសេសសម្រាប់តម្រូវការរបស់អ្នកផ្តល់សេវា និងអ្នកចូលរួម។
- អាចទាញយកបានសម្រាប់កែសម្រួលបន្ថែម។
- **មានប្រយោជន៍សម្រាប់៖** អ្នកផ្តល់សេវា NDIS និងអ្នកចូលរួមក្នុងការគ្រប់គ្រងការគាំទ្រផ្ទាល់ខ្លួនរបស់ពួកគេ ឬអ្នកទាំងនោះដែលពាក់ព័ន្ធនឹងការពណ៌នាតួនាទីគាំទ្រ។

## ការត្រួតពិនិត្យសមត្ថភាព

- ផ្តល់ការណែនាំជាក់ស្តែង និងឧបករណ៍នានាដើម្បីបង្កើនគុណភាព និងភាពស៊ីសង្វាក់គ្នានៃការត្រួតពិនិត្យ។
- ផ្តល់សន្លឹកព័ត៌មានគន្លឹះ បញ្ជីត្រួតពិនិត្យ និងទម្រង់គំរូនានាដើម្បីគាំទ្រដល់អ្នកដឹកនាំជាន់ខ្ពស់ អ្នកមើលការខុសត្រូវ បុគ្គលិក និងអ្នកចូលរួមនានាដើម្បីចូលរួមពាក់ព័ន្ធក្នុងការត្រួតពិនិត្យ។
- អនុញ្ញាតឱ្យទាញយក និងកែសម្រួលទម្រង់គំរូ និងឯកសារនានាដើម្បីបំពេញតម្រូវការបុគ្គល។
- **មានប្រយោជន៍ សម្រាប់៖ អ្នកផ្តល់សេវា** NDIS **អ្នកមើលការខុសត្រូវ បុគ្គលិក និងអ្នកចូលរួមនានានៅក្នុងដំណើរការមតិកែលម្អ និងការត្រួតពិនិត្យ។**

## ធនធានសម្រាប់ការជ្រើសរើសបុគ្គលិក និងការសម្រិតសម្រាំងបុគ្គលិក

- ផ្តល់ការណែនាំជាជំហានៗ និងគន្លឹះក្នុងការទទួលយកវិធីសាស្ត្រផ្អែកលើសមត្ថភាពក្នុងការជ្រើសរើសបុគ្គលិក និងការសម្រិតសម្រាំងបុគ្គលិក។
- ផ្តល់ព័ត៌មាន គន្លឹះជាក់ស្តែង ទម្រង់គំរូ និងសម្ភារៈមួយចំនួនសម្រាប់ដំណាក់កាលនីមួយៗនៃដំណើរការជ្រើសរើសបុគ្គលិក។
- អនុញ្ញាតឱ្យទាញយក និងកែសម្រួលទម្រង់គំរូ និងឯកសារនានាដើម្បីបំពេញបានសមស្របតាមតម្រូវការបុគ្គល។
- ផ្តត់ផ្តង់កំណែពីរដែលត្រូវតាមបុគ្គលជាពិសេសសម្រាប់តម្រូវការរបស់អ្នកផ្តល់សេវា និងអ្នកចូលរួម។
- **មានប្រយោជន៍សម្រាប់៖** អ្នកផ្តល់សេវា NDIS និងអ្នកចូលរួមក្នុងការគ្រប់គ្រងការគាំទ្រផ្ទាល់ខ្លួនរបស់ពួកគេ ឬអ្នកដែលចូលរួមក្នុងការគាំទ្រដែលទាក់ទិន។

# ឧបករណ៍ និងធនធាននានាសម្រាប់អ្នកផ្តល់សេវា

## សៀវភៅមគ្គុទេសក៍ស្តីពីការបណ្តុះបណ្តាលសមត្ថភាព

- ផ្តល់ដំបូន្មានដល់អ្នកផ្តល់សេវា NDIS លើការស្វែងរកប្រភេទក្នុងការបណ្តុះបណ្តាល ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍សមត្ថភាព។
- ផ្តល់ការណែនាំជាក់ស្តែងលើការពិនិត្យឡើងវិញលើសមត្ថភាពនានានៅក្នុងកម្លាំងពលកម្ម និងការវាយតម្លៃកន្លែងដែលមានចន្លោះប្រហោង។
- ជំហាននានាតាមរយៈវិធីស្វែងរកការបណ្តុះបណ្តាលដែលដោះស្រាយគម្លាតសមត្ថភាពនៅក្នុងកម្លាំងពលកម្មរបស់អ្នកផ្តល់សេវា។
- **មានប្រយោជន៍សម្រាប់៖** អ្នកផ្តល់សេវា NDIS ដែលកំពុងស្វែងរកការបង្កើនជំនាញកម្លាំងពលកម្មរបស់ពួកគេ និងធានាថាការបណ្តុះបណ្តាលត្រូវបានកំណត់គោលដៅទៅតាមតម្រូវការរបស់បុគ្គលិក និងផ្តោតលើសមត្ថភាព។

## ឧបករណ៍គ្រប់គ្រង និងរៀបចំផែនការកម្លាំងពលកម្ម

- គាំទ្រអ្នកផ្តល់សេវា NDIS ដើម្បីវាយតម្លៃការអនុវត្តការគ្រប់គ្រងកម្លាំងពលកម្មបច្ចុប្បន្នរបស់ពួកគេ និងរៀបចំផែនការសម្រាប់កម្លាំងពលកម្មដែលពួកគេត្រូវការឥឡូវនេះ និងនៅក្នុងពេលអនាគត។
- ផ្តល់ផែនការកម្លាំងពលកម្មលម្អិតដោយផ្អែកលើព័ត៌មានដែលបានបញ្ចូលទៅក្នុងឧបករណ៍។
- មានប្រយោជន៍ជាបញ្ជីត្រួតពិនិត្យដើម្បីបញ្ជាក់នូវអ្វីដែលត្រូវពិចារណាក្នុងរៀបចំផែនការកម្លាំងពលកម្ម និង/ឬជាប្រភពនៃគំនិតនានាអំពីរបៀបបញ្ចូលក្របខ័ណ្ឌទៅក្នុងដំណើរការរៀបចំផែនការ ដើម្បីដោះស្រាយបញ្ហាប្រឈមនៃកម្លាំងពលកម្ម និងបង្កើតយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ។
- មាននៅក្នុងសណ្ឋាន Excel ជាទម្រង់គំរូដែលអាចទាញយកបាន។
- **មានប្រយោជន៍សម្រាប់៖** អ្នកផ្តល់សេវា NDIS។

# តើក្របខ័ណ្ឌនេះទាក់ទងនឹងក្រមប្រតិបត្តិ និងបទដ្ឋានអនុវត្តយ៉ាងដូចម្តេចដែរ?

ក្របខ័ណ្ឌនេះត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់អ្នកចូលរួម អ្នកផ្តល់សេវា បុគ្គលិក និងអ្នកបណ្តុះបណ្តាល។

ក្រមប្រតិបត្តិរបស់ NDIS តម្រូវឱ្យបុគ្គលិក និងអ្នកផ្តល់សេវាផ្តល់ការគាំទ្រ NDIS ដើម្បី "ផ្តល់ការគាំទ្រ និងសេវាកម្មក្នុងលំនាំមួយប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពដោយមានការយកចិត្តទុកដាក់ និងជំនាញ"។

នៅក្រោមស្តង់ដារការអនុវត្ត អ្នកផ្តល់សេវាដែលបានចុះបញ្ជីត្រូវបានទាមទារនៅក្នុងម៉ូឌុលគ្រប់គ្រងធនធានមនុស្សដើម្បីបំពេញឱ្យបានតាមលទ្ធផល៖ *"តម្រូវការគាំទ្ររបស់អ្នកចូលរួមម្នាក់ត្រូវបានបំពេញដោយបុគ្គលិកដែលមានសមត្ថភាពទាក់ទងនឹងតួនាទីរបស់ពួកគេ មានគុណវុឌ្ឍិពាក់ព័ន្ធ ហើយមានជំនាញ និងបទពិសោធន៍ពាក់ព័ន្ធក្នុងការផ្តល់ការគាំទ្រដោយផ្តោតលើបុគ្គល។[1]"*

**ក្របខ័ណ្ឌនេះផ្តល់ការណែនាំ និងឧបករណ៍នានាដើម្បីគាំទ្រអ្នកផ្តល់សេវា NDIS ដើម្បីបំពេញបានតាមកាតព្វកិច្ចទាំងនេះ។**

# តើខ្ញុំអាចទាក់ទងអ្នកណាសម្រាប់ព័ត៌មានបន្ថែម?

សម្រាប់ព័ត៌មានបន្ថែមអំពីក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្មរបស់គណៈកម្មការ NDIS ឬការអនុវត្តរបស់វា សូមចូលមើលគេហទំព័រ ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម៖ ទំព័រដើមនៃក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម NDIS | សមត្ថភាពកម្លាំងពលកម្ម NDIS (ndiscommission.gov.au)។

**ទំនាក់ទំនងគម្រោង៖** contactcentre@ndiscommission.gov.au ឬ 1800 035 554។

[1] គម្រោងធានារ៉ាប់រងជនពិការថ្នាក់ជាតិ (សូចនាករគុណភាពសម្រាប់ស្តង់ដារការអនុវត្ត NDIS) គោលការណ៍ណែនាំ ឆ្នាំ 2018 (2021)។ គម្រោងធានារ៉ាប់រងជនពិការថ្នាក់ជាតិ (សូចនាករគុណភាពសម្រាប់ស្តង់ដារការអនុវត្ត NDIS) គោលការណ៍ណែនាំ ឆ្នាំ 2018 (legislation.gov.au)